**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៦ អនក្រ.បក.

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន នៃ ក្រសួងទេសចរណ៍

***

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សំ រេ ច

## ជំពូកទី ១

## ការកែសំរួលមុខងារ និង ភារកិច្ច

**មាត្រា ១ :** កែសំរួលត្រង់ចំណុចទី ១១ នៃមាត្រាទី ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍ ក្រសួងទេសចរណ៍ មានមុខងារនិងភារកិច្ចដូចតទៅ :

- ចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់ ÷
  - ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរ សណ្ឋាគារ ផ្ទះភ្ញៀវ រមណីយដ្ឋានទេសចរណ៍ និង កីឡាទេសចរណ៍ ។
  - ភោជនីយដ្ឋាន រង្គសាល ខារ៉ាអូខេ ឌីស្កូតែក ក្លឹបកំសាន្ត ម៉ាស្សា និង អាជីវកម្មសេវាកម្ម ផ្សេង១ទៀត ដែលមានឧបនិស្ស័យក្នុងការបំរើភ្ញៀវទេសចរ ។

## ជំពូកទី ២

## អំពីក្រុមអ្នកច្បាប់

**មាត្រា ២ :** បង្កើតក្រុមអ្នកច្បាប់របស់ក្រសួងទេសចរណ៍ចំណុះក្រសួង ដែលមានតួនាទី និង ភារកិច្ច ដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវ សហការជាមួយស្ថាប័នពាក់ព័ន្ធ តាក់តែងសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសសារាចរ បទបញ្ញត្តិផ្សេង១លើការងារទេសចរណ៍
- សិក្សាស្រាវជ្រាវ ពិនិត្យសេចក្តីព្រាងកិច្ចសន្យានានា ដែលពាក់ព័ន្ធ នឹងការងារទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** ក្រុមអ្នកច្បាប់ដឹកនាំដោយប្រធានក្រុមមួយរូប និង មានអ្នកច្បាប់មួយចំនួនជាសមាជិក ដែលជាមន្ត្រីមានក្របខ័ណ្ឌស្រាប់ ។

ាត្រា ៤ : ប្រធានក្រុមអ្នកច្បាប់មានឋានៈ និង បុព្វសិទ្ធិស្មើ នឹង ប្រធាននាយកដ្ឋាន ។ ប្រធានក្រុម មានភារកិច្ចដឹកនាំ និង ចាត់ចែងអនុវត្តតួនាទី ភារកិច្ច ដូចមានចែងក្នុងមាត្រា ២ នៃ អនុក្រឹត្យនេះ ។

## ជំពូកទី ៣
## នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន

មាត្រា ៥ : តំលើងការិយាល័យសហប្រតិបត្តិការអន្តរជាតិ ចំណុះនាយកដ្ឋានផែនការអភិវឌ្ឍន៍នៃ អគ្គនាយកដ្ឋានទេសចរណ៍ ទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន នៃអគ្គនាយកដ្ឋានទេសចរណ៍ ដែលមានតួនាទី និង ភារកិច្ចដូចខាងក្រោម :

- សិក្សារៀបចំ នយោបាយ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍នៅក្នុងក្របខ័ណ្ឌការងារ អាស៊ាន
- អនុវត្តលើការងារ កិច្ចសហប្រតិបត្តិការ អន្តរជាតិ
- សហប្រតិបត្តិការជាមួយ អង្គការ សមាគម និង ស្ថាប័នអន្តរជាតិនានាលើវិស័យ ទេសចរណ៍ នៅក្នុងក្របខ័ណ្ឌអាស៊ាន និង អន្តរជាតិ
- ចងក្រង និង ធ្វើសេចក្តីព្រាង ព្រមទាំងរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង អនុស្សរណៈ កំណត់ហេតុ រវាងក្រសួងទេសចរណ៍នៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយ ស្ថាប័នទេសចរណ៍ នៅក្នុងតំបន់ និង ប្រទេសនានាលើសកលលោក
- ទំនាក់ទំនងជាមួយស្ថានទូត និង ក្រសួងនានាលើការងារអន្តរជាតិ
- សហការរៀបចំការប្រជុំ សិក្ខាសាលា និង ពិធីផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង

មាត្រា ៦ : នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន ដឹកនាំដោយ ប្រធានមួយរូប និង អាចមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៧ :** ការរៀបចំតួនាទី ភារកិច្ច និង ការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ចំណុះក្រុមអ្នកច្បាប់ និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ